ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

**ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ អន្តរាគមឲ្យដោះលែងពលរដ្ឋខ្មែរ២នាក់**

------------

ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃ កំពុងអន្តរាគមតាមមធ្យោបាយផ្លូវច្បាប់ ដើម្បីជួយឲ្យមានការដោះលែងពលរដ្ឋខ្មែរចំនួន**២នាក់** (ជាបងប្អូនបង្កើតនឹងគ្នា) ដែលត្រូវបានអាជ្ញាធរថៃ ចាប់ឃុំខ្លួននៅពន្ធនាគារខេត្តសាកែវ ពីបទប្រើប្រាស់ឯកសារក្លែងបន្លំចូលទឹកដីថៃដោយខុសច្បាប់។ កិច្ចអន្តរាគមន៍នេះធ្វើឡើង ឆ្លើយតបតាមពាក្យបណ្តឹងរបស់ឪពុកម្តាយពលរដ្ឋទាំងពីរនាក់ កាលពីថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១៧។

នៅថ្ងៃទី១៨ ខែឧសភា មន្ត្រីស្ថានអគ្គកុងស៊ុលបានទៅជួបផ្ទាល់ជាមួយបុរសរងគ្រោះ ដែលមានឈ្មោះ **ឃុិន ម៉ាន់** អាយុ២២ឆ្នាំ និងឈ្មោះ **ឃុិន អេន** អាយុ១៨ឆ្នាំ មកពីស្រុកថ្មគោល ខេត្តបាត់ដំបង។ អ្នកទាំងពីរ បានចូលទឹកដីថៃតាមរយៈមេខ្យល់ម្នាក់ជាជនជាតិខ្មែរ ដោយប្រើប្រាស់ប័ណ្ណចេញ-ចូលអន្តោប្រវេសន៍ថៃ ( ចូលព្រឹក ចេញល្ងាច សម្រាប់ពលរដ្ឋខ្មែរចូលផ្សាររោងក្លឿ) ដែលជាឈ្មោះអ្នកដទៃ ហើយត្រូវបានប៉ូលីសអន្តោប្រវេសន៍ថៃឃាត់ខ្លួន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ និងបញ្ជូនបន្តទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តសាកែវ នៅថ្ងៃទី២៧ ខែមេសា។

ស្ថានអគ្គកុងស៊ុល បានពិគ្រោះយោបល់ជាមួយមេធាវីជនជាតិថៃ និងក្រុមគ្រួសារជនរងគ្រោះ ដោយសម្រេចតម្កល់ប្រាក់ធានាខ្លួនអ្នកទាំងពីរឲ្យស្ថិតនៅក្រៅឃុំ រង់ចាំតុលាការកាត់ក្តីនាពេលខាងមុខ។

ស្ថានអគ្គកុងស៊ុល កំពុងបន្តតាមដានលើករណីនេះ ហើយនឹងផ្តល់ព័ត៌មានបន្ថែម នៅពេលក្រោយ។

ភ្នំពេញ, ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ២០១៧
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ